ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ៖៦៧៧/២២-៧-២០១៤

សាលដីកា

លេខ៖៧៨ក្រIVអ/១៧-១០-២០១៤

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើ តាមព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី ១៧-១០-២០១៤ ដែលមានសមាសភាពដូចតទៅ៖

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងសុំស្រូបទោស នៃរឿងព្រហ្មទណ្ឌ លេខ ៦៧៧ ចុះថ្ងៃ២២-៧-២០១៤ ដែលមាន :

១-ទណ្ឌិតឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី ១ នៃអគ្គនាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ ។

-ទណ្ឌិតរូបនេះត្រូវបានសាលាឧទ្ធរណ៍ បើកសវនាការជំនុំជម្រះលើសំណុំរឿង២ករណីផ្សេងៗគ្នា ។

**សំណុំរឿងទី ១**

**សំណុំរឿងព្រហ្មទណ្ឌលេខ ៥៤៣ ចុះថ្ងៃទី១៩-តុលា-២០១០ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានជនជាប់ចោទ**

១-ឈ្មោះ [redacted] ចាន់កេសរ ភេទស្រី កើតឆ្នាំ១៩៧៧ ជាតិខ្មែរ មុខរបរនៅផ្ទះ

២-ឈ្មោះ [redacted] អៀង ភេទប្រុស ជាតិខ្មែរ កើតឆ្នាំ១៩៦៩

៣-ឈ្មោះ [redacted] ដាន ភេទប្រុស កើតឆ្នាំ១៩៦៩ ជាតិខ្មែរ មុខរបរធ្វើចំការ

៤-ឈ្មោះ [redacted] សារ៉ាត់ ហៅ ហេង ភេទប្រុស កើតឆ្នាំ ១៩៥៣ ជាតិខ្មែរ

៥-ឈ្មោះ [redacted]ចាន់ធា ហៅ ណយ ភេទស្រី ជាតិខ្មែរ កើតឆ្នាំ១៩៧៨

៦-ឈ្មោះ [redacted]វណ្ណា ភេទប្រុសអាយុ កើតឆ្នាំ១៩៧៥ ជាតិខ្មែរ មុខរបរនគរបាលបង្ក្រាបគ្រឿងញៀន

ត្រូវបានដាក់ក្រោមការពិនិត្យពីបទ: លក់ដូរគ្រឿងញៀនច្រើនដង ប្រព្រឹត្តនៅភូមិសាស្ត្រ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីដើមឆ្នាំ២០០៦ ដល់ថ្ងៃទី១១-១០-២០១០ តាមមាត្រា ៣៣ថ្មី កថាខណ្ឌ ២ ចំណុច ក នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៣៤"ច" ចុះថ្ងៃទី១៧ ឧសភា ២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោម៖

១-ផ្តន្ទាទោសលើ:

ក.ឈ្មោះ [redacted]ចាន់កេសរ ភេទស្រី កើតឆ្នាំ១៩៧៧ ដាក់ពន្ធនាគារកំណត់ ៨(ប្រាំបី)ឆ្នាំ ។

ខ.ឈ្មោះ [redacted]ផាន ភេទប្រុស កើតឆ្នាំ១៩៦៩ ដាក់ពន្ធនាគារកំណត់ ៥(ប្រាំ)ឆ្នាំ ។

គ.ឈ្មោះ [redacted]អៀង ភេទប្រុស កើតឆ្នាំ១៩៦៩ ដាក់ពន្ធនាគារកំណត់ ២(ពីរ)ឆ្នាំ ។

ឃ.ឈ្មោះ [redacted] សារ៉ាត់ ភេទប្រុស ហៅ ហេង កើតឆ្នាំ ១៩៥៣ និងឈ្មោះ [redacted] ចាន់ធា ហៅ ណយ ភេទស្រី កើតឆ្នាំ ១៩៧៨ ដាក់ពន្ធនាគារកំណត់ ១០(ដប់)ឆ្នាំ ។

ពីបទ: ជួញដូរគ្រឿងញៀនខុសច្បាប់(ប្រព្រឹត្តច្រើនដង) ប្រព្រឹត្តនៅភូមិសាស្ត្រ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីដើមឆ្នាំ២០០៦ ដល់ដើមឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៣ថ្មី កថាខណ្ឌ២ ចំណុច ក នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៥ ។

២-ផ្តន្ទាទោសលើឈ្មោះ [redacted]វណ្ណា ភេទប្រុស កើតឆ្នាំ ១៩៧៥ ដាក់ពន្ធនាគារកំណត់ ៨(ប្រាំបី)ឆ្នាំ ពីបទ: ជួញដូរគ្រឿងញៀនខុសច្បាប់ (ប្រព្រឹត្តច្រើនដង) ប្រព្រឹត្តនៅភូមិសាស្ត្រ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីដើមឆ្នាំ២០០៦ ដល់ថ្ងៃទី១១-១០-២០១០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា៣៣ថ្មី កថាខណ្ឌ២ ចំណុច ក នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០០៥ ។

៣-សម្រេចចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] សារ៉ាត់ ហៅ ហេង ភេទប្រុស កើតឆ្នាំ១៩៥៣ និងឈ្មោះ [redacted] ចាន់ធា ហៅ ណយ ភេទស្រី កើតឆ្នាំ ១៩៧៨ ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ ។

៤-វត្ថុតាងមាន: កំព្យូទ័រយួរដៃ (Laptop) ម៉ាក Lenovo ពណ៌ទឹកប្រាក់ លេខ S/N:EB 07093-554 P/N:R3N037B17437 Model Name 7757 ចំនួនមួយគ្រឿង ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

៥-សំភារៈផ្ទាល់ខ្លួនមាន៖ រូបថតទំហំ ១.៥០ម x ០.៨០ម មានរូបចំនួន៦នាក់ ចំនួនមួយសន្លឹក , វិក័យប័ត្រធនាគារអេស៊ីលីដា ភីអិលស៊ី ចំនួនមួយសន្លឹក, រូបថតទំហំ ០.៨ម x ០.៦ម ចំនួនបីសន្លឹក , រូបថតតូចចំនួនដប់អាល់ប៊ុមតូច និងពីរអាល់ប៊ុមធំ ត្រូវប្រគល់ឱ្យម្ចាស់ដើមឈ្មោះ [redacted] ចាន់កេសរ វិញ ។

៦-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី ២៥-៤-២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧-៥-២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចាន់កេសរ , ឈ្មោះ [redacted] ផាន , ឈ្មោះ [redacted] អៀង , ឈ្មោះ [redacted] វណ្ណា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារ៉ាត់ និងឈ្មោះ [redacted] ចាន់ធា ។

ទុកសិទ្ធិឱ្យប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-សំណុំរឿងព្រហ្មទណ្ឌលេខ ៧១១ ចុះថ្ងៃទី ២៣-៧-២០១២ របស់សាលាឧទ្ធរណ៍ ។

សាលាឧទ្ធរណ៍ បានសម្រេចតាមអំណាច សាលដីកាព្រហ្មទណ្ឌ លេខ ៧៨ក្រVI"ឃ" ចុះថ្ងៃ២៤-ធ្នូ-២០១៣ ដែលមានខ្លឹមសារដូចតទៅ៖

១-ទទួលបណ្តឹង ចុះថ្ងៃទី២៨-៥-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ចាន់កេសរ, បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០-៥-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា និងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃ១៥-៦-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ផាន ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌ លេខ ៣៤ "ច" ចុះថ្ងៃទី១៧-៥-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ លើកលែងតែចំណុចទី១ "ក"និង"ខ" និងចំណុចទី២ ត្រូវកែប្រែជាថ្មីថា៖

ក/កែប្រែទណ្ឌកម្មឈ្មោះ [redacted] ចាន់កេសរ មកត្រឹមចំនួន ០៤ឆ្នាំ វិញ ។

ខ/កែប្រែទណ្ឌកម្មលើឈ្មោះ [redacted] ផាន មកត្រឹមចំនួន ០៤ឆ្នាំ វិញ ។

គ/កែប្រែទណ្ឌកម្មលើឈ្មោះ [redacted] វណ្ណា មកត្រឹមចំនួន ០៥ឆ្នាំ វិញ ។

ឃ/កែប្រែបញ្ញត្តិមាត្រា ៣៣ថ្មី កថាខណ្ឌទី២ ចំណុច "ក" មកមាត្រា ៣៣ថ្មី កថាខណ្ឌទី១ វិញ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់គ្រឿងញៀន ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៤-ចំណុចផ្សេងពីនេះ រក្សាទុកជាបានការដដែល ។

៥-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី២៤-១២-២០១៣ ចំពោះមុខមេធាវី និងជនជាប់ចោទ ។

## សំណុំរឿងទី ២

## សំណុំរឿងព្រហ្មទណ្ឌ លេខ ២២២ ចុះថ្ងៃ ១០-៥-២០១០ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានជនជាប់ចោទ

១-ឈ្មោះ [redacted] គួន ភេទប្រុស កើតឆ្នាំ១៩៦៩ សញ្ជាតិខ្មែរ មុខរបរយោធាវរៈសេនាធំលេខ ៥០៣

២-ឈ្មោះ [redacted] ភ័ណ ភេទប្រុស កើតឆ្នាំ១៩៧៨ សញ្ជាតិខ្មែរ មុខរបរគ្មាន

៣-ឈ្មោះ [redacted]វណ្ណា ភេទប្រុស កើតឆ្នាំ១៩៧៥ សញ្ជាតិខ្មែរ មុខរបរនគរបាលបង្ក្រាបគ្រឿងញៀន

៤-ឈ្មោះ [redacted]ផារ៉ា ភេទប្រុស កើតឆ្នាំ១៩៨៤ សញ្ជាតិខ្មែរ មុខរបរគ្មាន

ជាប់ចោទពីបទៈ ជួញដូរគ្រឿងញៀនខុសច្បាប់ តាមមាត្រា ៣៣ថ្មី ចំណុចទី២-ជ នៃច្បាប់ស្តីពីវិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនប្រព្រឹត្តនៅភូមិនិមិត្ត២ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១០ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៩៥ "ង" ចុះថ្ងៃទី០៨-៨-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោម៖

តាមសំអាងហេតុខាងលើ និង ក្រោយពីបានពិចារណាលើរាល់ភស្តុតាង និង សេចក្តីសន្និដ្ឋានទាំងអស់របស់ភាគី សាលាដំបូងខេត្តបន្ទាយមានជ័យ សម្រេចដូចខាងក្រោម៖

១/រកឃើញថា ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ភេទប្រុស កើតឆ្នាំ១៩៧៥, ឈ្មោះ [redacted] គួន ភេទប្រុស កើតឆ្នាំ១៩៦៩, ឈ្មោះ [redacted]ផារ៉ា ភេទប្រុស កើតឆ្នាំ១៩៨៤ និងឈ្មោះ [redacted]ភ័ណ ភេទប្រុស កើតឆ្នាំ១៩៧៨ មានពិរុទ្ធភាពពីបទៈ ជួញដូរគ្រឿងញៀនខុសច្បាប់ តាមមាត្រា ៣៣ថ្មី ចំណុចទី២-ជ នៃច្បាប់ស្តីពី វិសោធនកម្ម ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនប្រព្រឹត្តនៅភូមិនិមិត្ត២ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១០ ។

២/ផ្តន្ទាទោសជនជាប់ចោទ៖

-ឈ្មោះ[redacted] វណ្ណា ដាក់ពន្ធនាគារកំណត់ចំនួន ៧(ប្រាំពីរ)ឆ្នាំ ។

-ឈ្មោះ [redacted] ផារ៉ា ដាក់ពន្ធនាគារកំណត់ចំនួន ៦(ប្រាំមួយ)ឆ្នាំ គិតចាប់ពីថ្ងៃចាប់ខ្លួនយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ ។

-ឈ្មោះ [redacted] ភ័ណ និងឈ្មោះ [redacted] គួន ដាក់ពន្ធនាគារកំណត់ចំនួន ៥(ប្រាំ)ឆ្នាំ ដោយអនុវត្តទោសក្នុងពន្ធនាគារចំនួន ៣(បី)ឆ្នាំ ហើយមូលទោសលើសពីនេះត្រូវបានព្យួរទោសធម្មតា ។

៣/បង្គាប់ឱ្យចេញដីកាចាប់ខ្លួនឈ្មោះ[redacted]ផារ៉ា ភេទប្រុស កើតឆ្នាំ១៩៨៤ យកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ ។

៤/វត្ថុតាងរួមមាន៖

-ថ្នាំញៀនចំនួន ១៩៧២(មួយពាន់ប្រាំបួនរយចិតសិបពីរ)គ្រាប់ សម្រេចរឹបអូស និងបំផ្លាញចោល។

-រថយន្តម៉ាក TOYOTA LandCruiser ពណ៌ទឹកប៊ិច ចង្កូតឆ្វេង សេរីឆ្នាំ១៩៩៨ ពាក់ស្លាកលេខ នប២-៣៩៩៩ ចំនួន១(មួយ)គ្រឿង កូនស្លាកកុងតាក់រថយន្តចំនួន ១(មួយ), ទូរស័ព្ទដៃម៉ាកNokiaMolel ១២០២-២TypeRH១១២ និងស៊ីមលេខ ០៩២ ៦៧៧៧៨១ ចំនួន ១(មួយ)គ្រឿង, គ្រាប់អាវុធឡុកចំនួន

១៩(ដប់ប្រាំបួន)គ្រាប់, បង់គ្រាប់ចំនួន២(ពីរ), ប័ណ្ណនគរបាល២(ពីរ)សន្លឹក, ប័ណ្ណ អហ១ (មួយ)សន្លឹក សម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ ។

សាលក្រមនេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំងបីនាក់ និង កំបាំងមុខ ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា , ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**-សំណុំរឿងព្រហ្មទណ្ឌលេខ ១១០៩ ចុះថ្ងៃទី ២១-១១-២០១២ របស់សាលាឧទ្ធរណ៍ ។**

**សាលាឧទ្ធរណ៍ បានសម្រេចតាមអំណាច សាលដីកាព្រហ្មទណ្ឌ លេខ ៧៧ក្រVI"ឃ" ចុះថ្ងៃ២៤-ធ្នូ-២០១៣ ដែលមានខ្លឹមសារដូចតទៅ៖**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៤-៩-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណា ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌ លេខ ៩៥ "ង" ចុះថ្ងៃទី០៨-៨-២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ លើកលែងតែចំណុចទី១ត្រូវបដិសេធចោល និងចំណុចទី២ ស្តីពីទណ្ឌកម្មលើឈ្មោះ [redacted] វណ្ណា ត្រូវកែប្រែមកត្រឹមចំនួន ០៥ឆ្នាំ (ប្រាំឆ្នាំ) វិញ ពីបទៈ ជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិនិមិត្ត២ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨-៥-២០១០ ។ តាមមាត្រា ៣៣ថ្មី ចំណុចទី២-ជ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-ចំណុចផ្សេងពីនេះ រក្សាទុកជាបានការដដែល ។

៤-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

៥-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី២៤-១២-២០១៣ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងជនជាប់ចោទ ។

បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

**នាពេលសវនាការ**

-ទណ្ឌិតឈ្មោះ [redacted] វណ្ណា (វត្តមាន)

-លោក [redacted] វិបុល មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ (វត្តមាន)

**ប្រធានក្រុមប្រឹក្សាអានរបាយការណ៍ និងសង្ខេបរឿងជូនអង្គសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] វណ្ណា បានឆ្លើយថា៖ លើកទី១ ខ្លួនមិនដឹងថាជាគ្រឿងញៀនទេ នៅថ្ងៃ ៨-៥-២០១០ ខ្លួននៅក្រុងប៉ោយប៉ែត ។ ខ្លួនមិនប្រព្រឹត្តដូចការចោទប្រកាន់ទេ តែគេបានប្រើខ្លួន ឱ្យប្រមូលលុយឱ្យ [redacted] អៀង តែប៉ុណ្ណោះ ។ ខ្លួនមានមុខរបរជាមេឃ្យូគីថែមទៀត គេឱ្យលុយមកខ្លួនវិញចំនួន ២០០០$ ខ្លួនមិនដែលទាក់ទងពួក [redacted] អៀង ទៀតទេ ។

សំណូមពរៈ សុំលោកតុលាការមេត្តាទទួលការសុំស្រាបទោសឱ្យខ្ញុំបាទផង ។

៤៥៤

-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានៈ ក្រោយពីបានស្តាប់របាយការណ៍ ស្តាប់ការសួរដេញដោល និងពិនិត្យឯកសារ ក្នុងសំណុំរឿងមកឃើញថា ដោយជនជាប់ចោទឈ្មោះ [redacted] វណ្ណា ត្រូវបានផ្តន្ទាទោស២លើក តាមអំណាចសាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ដែលសរុបទោសគឺ ១០ឆ្នាំ ។ ការសុំស្រូបទោសរបស់ទណ្ឌិត [redacted] វណ្ណា នេះ មានលក្ខណៈត្រឹមត្រូវ តាមមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សុំក្រុមប្រឹក្សាពិចារណា និងសម្រេចតាមច្បាប់ ។

-មេធាវី [redacted] វិបុល ធ្វើសេចក្តីសន្និដ្ឋានៈ ក្រោយពីបានស្តាប់របាយការណ៍ ស្តាប់ការសួរដេញដោល ស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន និងបានពិនិត្យឯកសារក្នុងសំណុំរឿងមក គឺកូនក្តីខ្ញុំ [redacted] វណ្ណា មានសាលដីកាព្រហ្មទណ្ឌ ២ បានចូលជាស្ថាពរអស់ហើយ មានទោសសរុបចំនួន ១០ឆ្នាំ ។ សុំតុលាការសម្រេចស្រូបទោសទាំងពីរនេះបញ្ចូលគ្នា ។

សំណូមពរៈ សុំប្រធានក្រុមប្រឹក្សា និងក្រុមប្រឹក្សាទទួលយកការសុំស្រូបទោសនេះផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

-ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋាន ។

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់។

## <u>សាលាឧទ្ធរណ៍</u>

-យល់ឃើញថា ៖

១-ពាក្យសុំស្រូបទោស ចុះថ្ងៃ៨-៧-២០១៤ របស់ទណ្ឌិតឈ្មោះ [redacted] វណ្ណា ធ្វើឡើងត្រឹមត្រូវតាមច្បាប់ យោងតាមបញ្ញត្តិមាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

មេធាវី [redacted] វិបុល ការពារសិទ្ធិឱ្យឈ្មោះ ហ៊ឹម វណ្ណា ។

២-តាមសាលដីកាព្រហ្មទណ្ឌ លេខ៧៧ ក្រVI"ឃ" ចុះថ្ងៃ២៤-១២-២០១៣ របស់សាលាឧទ្ធរណ៍ បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារ ៥ឆ្នាំ ពីបទជួញដូរគ្រឿងញៀនខុសច្បាប់ ប្រព្រឹត្តនៅភូមិនិមិត្ត២ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃ០៨-៥-២០១០ តាមមាត្រា ៣៣ថ្មី ចំណុចទី២-៨ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ សាលដីកានេះបានចូលជាស្ថាពរហើយ ។

៣-តាមសាលដីកាព្រហ្មទណ្ឌ លេខ៧៨ ក្រVI"ឃ" ចុះថ្ងៃ២៤-១២-២០១៣ របស់សាលាឧទ្ធរណ៍ បានសម្រេចផ្តន្ទាទោសឈ្មោះ [redacted] វណ្ណា ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារ ៥ឆ្នាំ ពីបទជួញដូរគ្រឿងញៀនខុសច្បាប់ (ច្រើនដង) ប្រព្រឹត្តនៅភូមិសាស្ត្រ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយ

មានជ័យ កាលពីដើមឆ្នាំ២០០៦ ដល់ថ្ងៃ១១-១០-២០១០ តាមមាត្រា ៣៣ថ្មី កថាខ័ណ្ឌទី១ នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់គ្រឿងញៀន ។ សាលដីកានេះបានចូលជាស្ថាពរហើយ ។

៤-ទណ្ឌិតឈ្មោះ [redacted] វណ្ណា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ៥ឆ្នាំ តាមសាលដីកាស្ថាពរ លេខ ៧៧ ក្រVI“ឃ” ចុះថ្ងៃ២៤-១២-២០១៣ និង៥ឆ្នាំ តាមសាលដីកាស្ថាពរ លេខ ៧៨ ក្រVI“ឃ” ចុះថ្ងៃ២៤-១២-២០១៣ ពីបទជួញដូរគ្រឿងញៀនខុសច្បាប់ ។ ឃើញថា ទណ្ឌិត [redacted] វណ្ណា បានប្រព្រឹត្តបទល្មើស២លើក ហើយការចោទប្រកាន់ដាច់ពីគ្នា ។ ដូចនេះសាលាឧទ្ធរណ៍ ជាតុលាការចុងក្រោយ អាចប្រកាសស្រុបទោសបាន តាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ ។

៥-តាមសាលដីកាព្រហ្មទណ្ឌ លេខ ៤៨ ចុះថ្ងៃ១៥-២-២០១៣ របស់តុលាការកំពូលបានសម្រេចឱ្យស្រុបទោសពន្ធនាគារ ដែលប្រកាសលើឈ្មោះ ........ ៥ឆ្នាំ ក្នុងសាលក្រមលេខ ទៅក្នុងទោស៥ឆ្នាំ ក្នុងសាលដីកាលេខ......ទោសត្រូវអនុវត្ត គឺ ៥ឆ្នាំ ។ គប្បីបានជាយុត្តិសាស្ត្រ សម្រាប់អនុវត្ត ។

**ហេតុដូចនេះ វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងសុំស្រុបទោស ចុះថ្ងៃ៨-៧-២០១៤ របស់ឈ្មោះ [redacted] វណ្ណា ។

២-អោយស្រុបទោសពន្ធនាគារ ដែលប្រកាសលើឈ្មោះ [redacted] វណ្ណា ក្នុងសាលដីកាលេខ ៧៧ ក្រVI“ឃ” ចុះថ្ងៃ២៤-១២-២០១៣ ទៅក្នុងទោស៥ឆ្នាំ ក្នុងសាលដីកា លេខ ៧៨ក្រVI “ឃ” ចុះថ្ងៃ ២៤-១២-២០១៣ ទោសត្រូវអនុវត្តគឺ ៥ឆ្នាំ ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខទណ្ឌិត និងមេធាវីការពារសិទ្ធិ ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**សេចក្តីនេះព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់ គ្រប់តំណែង និងកំលាំងប្រដាប់អាវុធ ជួយសហការ អនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់** ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ២០១៥

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]